# កងយោធពលខេមរភូមិន្ទ

# អគ្គមេបញ្ជាការ

## ប្រវត្តិសង្ខេប

## កំណើតកងយោធពលខេមរភូមិន្ទ

*-សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈ គ្រប់ព្រះអង្គជាទីគោរពសក្ការៈ !*

*-សូមគោរព គណៈអធិបតី ជាទីគោរព !*

*-សូមគោរព ឯកឧត្តម នាយឧត្តមសេនីយ៍ផ្កាយមាស៤ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

*-ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយស ជាតិ អន្តរជាតិ ជាទីគោរព !*

*-អង្គមិទ្ទិងទាំងមូល ជាទីមេត្រី !*

## ខ្ញុំសូមអាននូវប្រវត្តិសង្ខេបកំណើតកងយោធពលខេមរៈភូមិន្ទ

## ប្រភពកំណើតកងយោធពលខេមរភូមិន្ទ

កងយោធពលខេមរភូមិន្ទ បានចាប់ផ្តើមកើតដំបូងចេញពីអនុសញ្ញាយោធាបារាំង-ខ្មែរ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៤៦ ដែលអនុសញ្ញានេះបានបញ្ជាក់ថា ប្រទេសកម្ពុជាត្រូវមានកម្លាំងយោធាដែលសុទ្ធតែជាខ្មែរ ។ សម័យកាលនោះ ព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ** ទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធលខេមរភូមិន្ទ ហើយទ្រង់បានមានព្រះបន្ទូលស័ង្កត់ធ្ងន់អំពីតួនាទីរបស់កងយោធពលខេមរភូមិន្ទ ថាៈ យើងមិនបានស្រលាញ់សង្គ្រាមទេ ព្រោះយើងបានទ្រាំទ្រអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ទន្ទឹមនឹងនោះវាបានផ្តល់នូវភាពអយុត្តិធម៌ និងភាពឃោរឃៅព្រៃផ្សៃដល់យើង ។ ប៉ុន្តែយើងបានត្រៀមខ្លួនជាស្រេច ដើម្បីប្រយុទ្ធរហូតដល់ដង្ហើមចុងក្រោយ ដើម្បីការពារឯករាជ្យភាព និងបូរណភាពទឹកដីរបស់យើង ។

អនុសញ្ញានេះ បានបញ្ជាក់អំពីបេសកកម្មរបស់កងយោធពលខេមរភូមិន្ទដូចតទៅ :

-ធានាអះអាងចំពោះអធិបតេយ្យភាពរបស់ព្រះករុណាព្រះចៅក្រុងកម្ពុជា

-គោរពច្បាប់ និងធានាសណ្តាប់ធ្នាប់សន្តិសុខផ្ទៃក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា

-ចូលរួមក្នុងកិច្ចការ ការពារព្រំដែននៃប្រទេសកម្ពុជា មិនតែប៉ុណ្ណោះបានគ្រោង និងបង្កើតសាលានាយទាហាន និងសាលានាយទាហានរងមួយសម្រាប់ធានាការបណ្តុះបណ្តាលគ្រប់ខ័ណ្ឌនេះ ។

កងយោធពលខេមរភូមិន្ទបានរីកចម្រើនខាងបរិមាណ និងគុណភាពក្នុងដំណាក់កាល៣ដាច់ពីគ្នា :

### ដំណាក់កាលទី១

ពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៤៦ មកដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៥៣ គឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមដំណាក់កាលផ្ទេរសមត្ថកិច្ចយោធារវាងប្រទេសបារាំង និងប្រទេសកម្ពុជា ។

ដំណាក់កាលនេះ គឺជាការបង្កើតអគ្គសេនាធិការនៃក្រសួងការពារជាតិ ក្រោមឱវាទរដ្ឋមន្ត្រី មានក្រុមគាំទ្រមានកងឯកភាពជើងគោកមួយចំនួន មានកងនាវាចរចម្បាំងតាមទន្លេចំនួន២កង ហើយមានសាលានិងមជ្ឈមណ្ឌល

ហ្វឹកហ្វឺន គឺជាសាលាយោធាខ្មែរសម្រាប់បណ្តុះបណ្តាលនាយទាហាន និងសាលាក្របខ័ណ្ឌ « ថ្មពេជ្រ » សម្រាប់បណ្តុះបណ្តាលនាយទាហានរង ។

**ដំណាក់កាលទី២**

ពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៥៣ ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ជារយៈកាលបញ្ចប់អាណានិគមលើទឹកដីអតីតឥណ្ឌូចិន របស់អាណានិគមបារាំងសែស។ ព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យពេញបរិបូរណ៍ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដោយចលនាទាមទាររបស់កងទ័ព ប្រជានុរាស្ត្រគ្រប់ស្រទាប់ជាន់ថ្នាក់ ក្រោមព្រះរាជបូជនីយកិច្ចដឹកនាំរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** និងក៏ជាថ្ងៃចាប់កំណើតដ៏ពិតប្រាកដនៃកងយោធពលខេមរភូមិន្ទ ។

ដំណាក់កាលនេះ ក៏ជាដំណាក់កាលដែលបញ្ជាការ និងកងកម្លាំងបារាំងសែសចាកចេញពីទឹកដីនៃប្រទេសជាតិយើង ។ នោះគឺជាការចាប់បដិសន្ធិពេញលក្ខណៈ នៃកងយោធពលខេមរភូមិន្ទ ។ នៅពេលនោះហើយដែលយើងបានបង្កើតអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ បញ្ជាការដ្ឋានកងទ័ពជើងអាកាសភូមិន្ទ បញ្ជាការដ្ឋានកងទ័ពជើងទឹកភូមិន្ទ ។

ក្រោមព្រះរាជបញ្ជាផ្ទាល់របស់ព្រះករុណា ព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ**កងយោធពលខេមរភូមិន្ទបានបង្ហាញនូវភាពអង់អាចមោះមុតក្នុងប្រតិបត្តិការសឹក រំដោះតំបន់ខ្លះពីកណ្តាប់ដៃពួកបរទេស និងពួកឧទ្ទាម ។ ប្រតិបត្តិការទាំងនេះប្រព្រឹត្តទៅនៅឆ្នាំ១៩៥៣ និងឆ្នាំ១៩៥៤ នៅខេត្តបាត់ដំបង « ប្រតិបត្តិការសាមគ្គី និងប្រតិបត្តិការប៉ៃលិន » និងនៅក្នុងឆ្នាំ១៩៥៤ នៅខេត្តក្រចេះ « ប្រតិបត្តិការព្រែកទេ និងស្រែ ជេស » ប្រតិបត្តិការទាំងនេះត្រូវបានបញ្ចប់ដោយបានបណ្តេញពួកឈ្លានពានដកថយចេញពីព្រំដែនប្រទេសយើង និងការបែកខ្ញែកចុងក្រោយរបស់ពួកឧទ្ទាម ។

ចាប់ផ្តើមពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ បន្ទាប់ពីប្រតិបត្តិការនានាបានបញ្ចប់ គឺជាដំណាក់កាលនៃការរៀបចំពង្រឹង គុណភាពកងយោធពលខេមរភូមិន្ទឡើងវិញ ។ ក្នុងនោះគេ សង្កេតឃើញមានការបង្កើតសាលាបណ្ឌិតសភាយោធា មជ្ឈមណ្ឌលហ្វឹកហ្វឺន បង្កើតកងឯកភាពគាំទ្រថ្មីៗជាច្រើន បង្កើតមូលដ្ឋានទ័ពអាកាស មានក្រុមអាកាសចរចំនួន៣ក្រុម និងមូលដ្ឋានបណ្តុះបណ្តាលទ័ពជើងទឹក ផ្នែកទន្លេ និងផ្នែកសមុទ្រ មានក្រុមកុម្ម៉ង់ដូ ម៉ារីនចំនួន ១ក្រុម និងមានកងរាជអាវុធហត្ថជាតិ។ល។

ពីឆ្នាំ១៩៥៤ ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងសម័យសង្គមរាស្ត្រនិយម កងយោធពលខេមរភូមិន្ទ បានរីកចម្រើននិងធំធាត់ បំពេញសម្រេចភារកិច្ចការពារមាតុភូមិប្រកបដោយប្រសិទ្ធភាព រក្សាការពារកម្ពុជាឱ្យមានឈ្មោះថាជា « កោះសន្តិភាព » នៅជ្រោយឥណ្ឌូចិន ។

-ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ កម្ពុជាបានធ្លាក់ក្នុងវិបត្តិនយោបាយយ៉ាងធ្ងន់ធ្ងរសង្គ្រាមផ្ទៃក្នុងបានផ្ទុះឡើងទូទាំងប្រទេស គូបដិបក្ខខ្មែរបែងចែកជាច្រើនក្រុម និងសុទ្ធតែមានកម្លាំងផ្សេងៗរៀងខ្លួន ។

-ឥទ្ធិពលនៃសង្គ្រាមដែលបានអូសបន្លាយជាង៣ទសវត្សរ៍ បានធ្វើអោយកម្ពុជាទទួលរងនូវភាពមហន្តរាយ និងឈឺចាប់ខ្លោចផ្សាយ៉ាងធ្ងន់ធ្ងរ ជាពិសេសនៅក្នុងទសវត្សរ៍ទី៧០នៃរបបសាធារណៈរដ្ឋ លន់ ណុល និងក្នុងរបប

ប្រល័យពូជសាសន៍ក្នុងរបប ប៉ុល ពត បានធ្វើអោយហេដ្ឋារចនាសម្ព័ន្ធជាតិត្រូវវិនាសអន្តរាយ អាយុជីវិតនិងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋត្រូវបាត់បង់ខ្ទេចខ្ទាំ អត្តសញ្ញាណជាតិ និងព្រលឹងជាតិស្ទើរលាយសាបសូន្យ ។ ចាប់ពីពេលនោះមក កងយោធពលខេមរភូមិន្ទត្រូវបានបំផ្លេចបំផ្លាញរលំរលាយ និងបាត់ឈ្មោះជាកងយោធពលខេមរភូមិន្ទផងដែរ ។

### ដំណាក់កាលទី៣

ចាប់ពីខែឧសភា ឆ្នាំ១៩៩៣ គឺជាដំណាក់កាលនៃការកសាង កងយោធពលខេមរភូមិន្ទឡើងវិញ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ស្តីពីដំណោះស្រាយនយោបាយរួមនៅកម្ពុជា បាន សម្រេចទៅដល់ការរៀបចំបោះឆ្នោតដោយសេរីនៅកម្ពុជា ( អ៊ុនតាក់ ) បង្កើតបានរដ្ឋធម្មនុញ្ញ ស្ថាប័នរដ្ឋសភា និង រាជរដ្ឋាភិបាលអណត្តិទី១ ។

### ការកសាងកងយោធពលខេមរភូមិន្ទឡើងវិញក្រោយឆ្នាំ១៩៩៣

កិច្ចចរចាស្វែងរកសន្តិភាព កើតឡើងជាច្រើនលើកច្រើនសារ រវាងសម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** និងព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្រួបបង្រួមផ្សះផ្សាជាតិ បញ្ចប់សង្គ្រាមនៅកម្ពុជា សំដៅស្វែងរកសន្តិភាព ។ ដោយមានអន្តរាគមន៍យ៉ាងពេញទំហឹង ពីសំណាក់អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ដែលបានត្រួសត្រាយផ្លូវ ភាគីខ្មែរទាំងអស់យល់ព្រមឈប់បាញ់គ្នាហើយចូលរួមក្នុងការបោះឆ្នោតជាសកលដោយសេរី ដែលរៀបចំឡើងដោយអ៊ុនតាក់ នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ លើកលែងតែភាគីខ្មែរក្រហម ដែលជាហត្ថលេខីមួយ បានធ្វើពហិការមិនចូលរួមឡើយ ពួកគេនៅតែបន្តកាន់កាប់ទឹកដីតំបន់មួយចំនួន ជាពិសេសនៅតាមព្រំដែនខាងលិចប្រទេស បង្កនិងអូសបន្លាយសង្គ្រាមតទៅទៀត ។

ទោះបីស្ថិតនៅក្នុងស្ថានភាពយ៉ាងដូច្នេះក្តី ភាគីទាំង៣ ក្នុងចំណោមភាគី៤ បានចូលរួមបោះឆ្នោតជាសកល បង្កើតបានរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា បង្កើតបានស្ថាប័នព្រះមហាក្សត្រ ។

ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់ឡើងគ្រងរាជ្យសម្បត្តិសាជាថ្មី ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៣ ។

ស្ថាប័នរដ្ឋសភា មានសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ជាប្រធាន និងគណបក្សនយោបាយ ដែលមានអសនៈក្នុងសភាបានព្រមព្រៀងគ្នាប្រកបដោយសុទិដ្ឋិនិយម ដើម្បីរៀបចំរដ្ឋាភិបាលចម្រុះអណត្តិទី១ ដឹកនាំដោយសហនាយករដ្ឋមន្ត្រីសម្តេចក្រុមព្រះ**នរោត្តម រណឫទ្ធិ**និងសម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** ។

### ដំណោះស្រាយក្នុងការរៀបចំស្ថាប័នកងទ័ពវិញ

ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ គឺដំណើការកសាងកងយោធពលខេមរភូមិន្ទ ដែលជាកងកម្លាំងរបស់ជាតិ មានតួនាទីអព្យាក្រិតក្នុងមុខនាទី ក្នុងការងារ ។ ការរៀបចំនេះគឺអនុវត្តន៍តាមរូបមន្ត បង្រួបបង្រួម កងកម្លាំងប្រដាប់អាវុធមកពីភាគីទាំង៣ ដែលជាការរៀបចំមួយមិនគ្រាន់តែអនុលោមទៅតាមកម្លាំង នៃកងទ័ពរបស់ភាគីនិមួយៗ ប៉ុណ្ណោះទេ តែក៏ជាការសម្របសម្រួលទៅតាមអំណាចផ្នែកនយោបាយផងដែរ ។

-ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៣ ឯកឧត្តម ឧត្តមសេនីយ៍ឯក **កែ គីមយ៉ាន** ត្រូវបានតែងតាំងជា នាយអគ្គសេនាធិការកងទ័ពជាតិកម្ពុជា ដោយព្រះរាជក្រឹត្យឡាយព្រះហត្ថលេខាដោយព្រះបាទសម្តេច **នរោត្តម សីហនុ** ។

យោងតាមរដ្ឋធម្មនុញ្ញមាត្រាទី២៣ បានចែងថាៈ ព្រះមហាក្សត្រ ទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើង ដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទទាំងមូល ។

-ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ បានបង្កើតឡើងតាមព្រះរាជក្រឹត្យឡាយព្រះហស្តលេខាដោយ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ។ សហនាយករដ្ឋមន្ត្រីទាំងពីរជា សហអគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា ។

អគ្គបញ្ជាការដ្ឋានជាស្ថាប័នខ្ពស់បំផុតនៅក្នុងឋានានុក្រម កងយោធពលខេមរភូមិន្ទ និងជាមូលដ្ឋានសម្រាប់ធ្វើការសម្របសម្រួលរវាងអគ្គសេនាធិការ និងក្រសួងការពារជាតិផងដែរ ។ ទោះបីដូច្នេះក្តី ការដឹកនាំបញ្ជាកងទ័ពទាំងមូលនៅតែជាការទទួលខុសត្រូវរបស់អគ្គសេនាធិការដដែល ។

ក្រោមការដឹកនាំរបស់ក្រសួងការពារជាតិ អគ្គសេនាធិការបានចាត់វិធានការជាបន្ទាន់ក្នុងការបង្រួបបង្រួមកងទ័ពរបស់ភាគីទាំង៣ ដើម្បីរៀបចំកសាង កងយោធពលខេមរភូមិន្ទឡើងវិញ ដោយទទួលស្គាល់កងទ័ពមកពីអតីតរដ្ឋកម្ពុជា អតីតកងទ័ពភាគីហ្វ៊ុនស៊ិនប៉ិច អតីតកងទ័ពរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ កងកម្លាំងទាំងបីភាគីនេះត្រូវបានរៀបចំបញ្ចូលគ្នាទៅជាកងពលធំ កងពលតូច វរសេនាធំ តាមរចនាសម្ព័ន្ធ របស់អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ដែលជាកងទ័ពជាតិតែមួយគត់ បានប្រសូត្រចេញជារូបរាងប្រកបដោយជោគជ័យគួរឱ្យស្ញើចសរសើរ ។

## ស្នាដៃរបស់កងយោធពលខេមរភូមិន្ទក្នុងបុព្វហេតុដើម្បីសន្តិភាព

## ស្នាដៃក្នុងការអនុវត្តន៍ នយោបាយឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងដំណាក់កាលនេះ ដោយរាជរដ្ឋាភិបាលប្រឈមមុខនឹងភាគីខ្មែរក្រហម ដែលនៅបន្តកាន់កាប់តំបន់មួយចំនួនតាមព្រំដែន ភាគខាងលិច បន្តបង្កសង្គ្រាមផ្ទៃក្នុងរវាងខ្មែរ និងខ្មែរតទៅទៀត និងដោយប្រតិបត្តិតាមរដ្ឋធម្មនុញ្ញមាត្រាទី៣ ជំពូក១ដែលបានចែងថា« ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋមិនអាចបំបែកបាន » កងយោធពលខេមរភូមិន្ទមានតួនាទីសំខាន់ និងចាំបាច់បំផុតក្នុងការទប់ស្កាត់បង្ក្រាបនូវរាល់សកម្មភាពរបស់ពួកឧទ្ទាមខុសច្បាប់ អំពើភេរវកម្ម និងសកម្មភាពអសន្តិសុខផ្សេងៗទៀត ។ យុទ្ធជន យុទ្ធនារី នៃកងយោធពលខេមរភូមិន្ទចាំបាច់ត្រូវធ្វើពលិកម្មគ្រប់បែបយ៉ាងទាំងអាយុជីវិត ទាំងកម្លាំងកាយចិត្ត ដើម្បីបុព្វហេតុសន្តិភាព សេរីភាព និងសេចក្តីសុខសាន្តរបស់ប្រជាពលរដ្ឋ ។ ក្នុងការអនុវត្តន៍តួនាទីភារកិច្ចចម្បងរបស់ខ្លួន ដែលស្ថិតក្នុងស្ថានភាពដ៏លំបាកស្មុគ្រស្មាញនេះ កងយោធពលខេមរភូមិន្ទ ត្រូវពុះពារឧបស័គ្គគ្រប់បែបយ៉ាង ព្រមទាំងចំណាយធនធានដ៏ច្រើនក្នុងប្រតិបត្តិការសឹកដើម្បីធានាឱ្យបានទាំងស្រុងនូវសន្តិភាព ការពាររដ្ឋធម្មនុញ្ញ និងរាជរដ្ឋាភិបាលស្របច្បាប់ ដែលប្រសូត្រចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ។

ស្ថិតក្នុងឱកាសអំណោយផលពីសភាពការណ៍អន្តរជាតិ សភាពការណ៍ផ្ទៃក្នុងប្រទេស និងសភាពការណ៍ផ្ទៃក្នុងរបស់ខ្មែរក្រហម សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានដាក់ចេញនយោបាយឈ្នះ ឈ្នះ ក្នុងឆ្នាំ១៩៩៥ ។ គោលដៅចម្បងនៃនយោបាយនេះ គឺបញ្ចប់ការបង្ហូរឈាមគ្នា ធ្វើការបង្រួបបង្រួមស្វែងរកសន្តិភាពពេញលេញ ពិតប្រាកដជូនមាតុភូមិកម្ពុជា ។

ដោយពលិកម្មដ៏ធំធេង និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល រួមជាមួយប្រភពធនធានដែលបានចំណាយ ជោគជ័យត្រចេះត្រចង់បានលេចចេញជារូបរាងក្នុងឆ្នាំ១៩៩៦នោះ គឺការផ្តាច់ខ្លួនទាំងផ្ទាំងៗចាប់ពីភូមិសាស្ត្រខេត្តកំពត រហូតភាគខាងជើងផ្លូវជាតិលេខ៥ រួមមានតំបន់ភ្នំវល្លិ៍ តំបន់ភ្នំឱរ៉ាល់ តំបន់អន្លង់វែង តំបន់ប៉ៃលិន តំបន់អន្លង់វែង ឧត្តរមានជ័យ ស្រែវាល កម្លាំងខ្មែរក្រហមត្រូវទទួលចូលក្នុងកងយោធពលខេមរភូមិន្ទចំនួន ៣វរណសិរ្ស ៣៩កងពលធំ ៤កងពលតូច ៣វរសេនាធំ និងមន្ទីរចំណុះ នេះគឺជាការរលំរលាយទាំងស្រុងនូវអង្គការចាត់តាំង នយោបាយយោធារបស់ខ្មែរក្រហម និងបង្ហាញឱ្យឃើញនូវប្រសិទ្ធភាពនៃនយោបាយឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានកងយោធពលខេមរភូមិន្ទ ជាស្នូលក្នុងការអនុវត្តន៍ ។

## ស្នាដៃក្នុងការអនុវត្តន៍ភារកិច្ចរួមចំណែកការពារកសាងអភិវឌ្ឍន៍មាតុភូមិ

តួនាទី និងសកម្មភាពសំខាន់ផ្សេងៗទៀតរបស់កងយោធពលខេមរភូមិន្ទ ក្នុងការការពារ កសាង អភិវឌ្ឍន៍ប្រទេសជាតិ ក្នុងដំណាក់កាលដំបូងនេះ ក៏ត្រូវបានកោតសរសើរទទួលស្គាល់ និងកត់ត្រាក្នុងកំណត់ហេតុប្រវត្តិសាស្ត្រផងទ័ពផងដែរ ជាអាទិ៍ក្នុងការអនុវត្តន៍តួនាទីភារកិច្ចស្នូល ការពារជាតិមាតុភូមិនិងប្រជាជន ការពារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមជាតិ ក្នុងនោះការចូលរួមចំណែកធ្វើអោយដំណើរការនៃការបោះឆ្នោតសកល អណត្តិទី១នាឆ្នាំ១៩៩៣ ប្រព្រឹត្តទៅប្រកបដោយភាពរលូន និងមានសន្តិសុខ១០០% សហការយ៉ាងស្អិតរមួតជាមួយកម្លាំងសមត្ថកិច្ចជំនាញ រួមនឹងកម្លាំងប្រជាជនអាជ្ញាធរមូលដ្ឋានទប់ស្កាត់ការពារ និងបង្ក្រាបបទឧក្រិដ្ឋ បទល្មើសនានា សកម្មភាពភេរវកម្ម វិទ្ធ្វំសកម្ម។ល។ ការចូលរួមទ្រទ្រង់កម្ពុជាអោយទៅ ជានីតិរដ្ឋពង្រឹងលទ្ធិប្រជាធិបតេយ្យពង្រឹងស្ថិរភាពនយោបាយ បង្កលក្ខណៈនិងបរិស្ថានសន្តិសុខ អោយដំណើរការនៃការស្តារកសាង និងអភិវឌ្ឍន៍ជាតិប្រក្បដោយចីរភាព ។ ក្រៅពីភារកិច្ចស្នូល កងយោធពលខេមរភូមិន្ទក៏បានចូលរួមស្តារកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ដូចជាការជួសជុលស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ វត្តអារាម ប្រព័ន្ធធារាសាស្ត្រទំនប់ប្រឡាយ ។ល។ និងបានចូលរួមជួយប្រជាជន ក្នុងជីវភាពរស់នៅ បង្កបង្កើនផល ជួយប្រជាជនក្នុងពេលជួបគ្រោះអាសន្ន គ្រោះមហន្តរាយផ្សេងៗ ខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួតជាហូរហែផងដែរ ។

ដោយឡែកលើការកែទម្រង់កងយោធពលខេមរភូមិន្ទ ពុះពារអនុវត្តទទួលបានលទ្ធផលយ៉ាងល្អប្រសើរគួរអោយកត់សំគាល់ ជាពិសេសក្នុងការកែទម្រង់អំពីបរិមាណ ការកាត់រំសាយកងទ័ព ការកែទម្រង់រចនាសម្ព័ន្ធក្បាលអង្គភាព ស្ថាប័ន ការកាត់បន្ថយនិងការទប់ស្កាត់អតិផរណាស័ក្តិ។ល។ ទន្ទឹមនោះការកែទម្រង់ អំពីផ្នែកគុណភាពកងយោធពលខេមរភូមិន្ទ ក៏បានពង្រឹងនិងពង្រីកប្រព័ន្ធការងារហ្វឹកហ្វឺន តាមរូបភាពបង្កើនសាលាហ្វឹកហ្វឺន វិទ្យាស្ថាន សកលវិទ្យាល័យគ្រប់ជំនាញតាមលំដាប់ថ្នាក់ ចាត់បញ្ជូននាយទាហាន ពលទាហាន អោយទៅហ្វឹកហ្វឺនរៀនសូត្រ បំប៉ិនបណ្តុះបណ្តាល អំពីជំនាញបច្ចេកទេសវិទ្យាសាស្ត្រទាំងក្នុង និងក្រៅប្រទេស ដើម្បីបង្កើនសមត្ថភាពក្នុង

ការសម្រេចភារកិច្ចស្មុគស្មាញ ប្រកបដោយប្រសិទ្ធភាព ប្រែក្លាយកងយោធពលខេមរភូមិន្ទ អោយទៅជាកងទ័ពរៀបរយ រឹងមាំស្តង់ដារអន្តរជាតិ ។

ក្នុងដំណាក់កាលចាប់បដិសន្ធិជាថ្មីឡើងវិញនេះ លើការងារទំនាក់ទំនងអន្តរជាតិ កងយោធពលខេមរភូមិន្ទ បាននិងកំពុងធ្វើសមាហរណកម្ម ព្រមទាំងពង្រឹងពង្រីកយ៉ាងរឹងមាំ កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយកងទ័ព នៃបណ្តាប្រទេសជិតឆ្ងាយនៅក្នុងតំបន់និងនៅលើសកលលោក សំដៅសន្តិសុខលើគ្រប់ផ្នែក ក៏ដូចជាដើម្បីធ្វើការអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ អោយបានរីកចម្រើនរឹងមាំផងដែរ ។

*គណាធិបតី ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ជាទីគោរព!*

ទាំងអស់ខាងលើនេះ គឺជាកំណត់ហេតុយ៉ាងសង្ខេបនៃកាលប្រវត្តិរបស់កងយោធពលខេមរភូមិន្ទ អំពីថ្ងៃចាប់បដិសន្ធិគ្រាដំបូង អំពីដំណាក់កាលនៃការរលំរលាយបាត់បង់ទៅវិញ និងអំពីដំណាក់កាលចាប់បដិសន្ធិឡើងវិញ ព្រមទាំងសកម្មភាពនិងស្នាដៃសំខាន់ៗនៅក្នុងគ្រប់ដំណាក់កាល ជាពិសេសដំណាក់កាលដែលកងយោធពលខេមរភូមិន្ទ ចាប់បដិសន្ធិឡើងវិញ ។

ប្រជាជាតិយើងនិងកងយោធពលខេមរភូមិន្ទទាំងមូល មានមោទនភាពយ៉ាងក្រៃលែង ជាមួយកិត្តិយសដ៏ថ្លៃថ្លាដ៏ឧត្តុង្គឧត្តមរបស់រៀមច្បងកងយោធពលខេមរភូមិន្ទជំនាន់មុន ក៏ដូចជាចំពោះការចាប់បដិសន្ធិជាថ្មី ប្រកបដោយភាពរីកចម្រើនរឹងមាំរបស់កងយោធពលខេមរភូមិន្ទយើង នាដំណាក់កាលថ្មីបច្ចុប្បន្ន ។

*សូមអរព្រះគុណ និងអរគុណ!*